មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ យុន វ៉ន ភេទស្រី អាយុ៦០ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ “យោធា”**

**ស្រុកកំណើតនៅភូមិស្គុល ឃុំស្មោង ស្រុកទ្រាំង ខេត្តតាកែវ**

**រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ម៉ម សុវណ្ណ**

**០១:០២:៤០**

**៣១ទំព័រ**

សុវណ្ណៈ ចឹងជាដំបូងខ្ញុំសូមជំរាបសួរមីង ។

វ៉នៈ ចាស ។

សុវណ្ណៈ ខ្ញុំសូមណែនាំខ្លួនខ្ញុំឲ្យស្គាល់ខ្ញុំឈ្មោះ សុវណ្ណ ខ្ញុំជាបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាកន្លែងមួយដែលធ្វើការចងក្រងទាក់ទងនិងរបបខ្មែរក្រហម ។

វ៉នៈ ចាស ។

សុវណ្ណៈ ឬយើងហៅថា របបបីឆ្នាំ៨ខែម្ភៃថ្ងៃ ចឹងខ្ញុំចុះមកលើនេះថ្ងៃទី១៩ខែ១២ឆ្នាំ២០១៣នៅក្នុងស្រុកត្រពាំងប្រាសាទនេះ ដើម្បីជួបឆ្លងកាត់អំពីជីវិតរបស់មីង តាំងពីមុនមករហូតដល់ពេលបច្ចុប្បន្ន តើជីវិតមានការប្រែប្រួលយ៉ាងម៉េចខ្លះ ដើម្បីខ្ញុំដឹងពូរឿងរ៉ាវទាំងអស់ហ្នឹងយកទៅសរសេរជាប្រវត្តិឬសរសេរចងក្រងទាក់ទងជាមួយស្រុកត្រពាំងប្រាសាទហ្នឹង ចឹងជាដំបូងខ្ញុំចង់ឲ្យអ៊ីណែនាំខ្លួនទៅ ថា អ៊ីឈ្មោះអីគេដែរ មីងឈ្មោះអីគេដែរ?

វ៉នៈ ខ្ញុំឈ្មោះ យុន វ៉ន ។

សុវណ្ណៈ មីងសព្វថ្ងៃអាយុប៉ុន្មាន?

វ៉នៈ ខ្ញុំអាយុ៦០ឆ្នាំមមែ៦០ហើយ ។

សុវណ្ណៈ មីងកើតឆ្នាំប៉ុន្មាន?

វ៉នៈ មើលខ្ញុំកើតឆ្នាំ១៩៥៥ ។

សុវណ្ណៈ សព្វថ្ងៃមីងធ្វើអីគេ?

វ៉នៈ ខ្ញុំធ្វើស្រែចម្ការហ្នឹង ទើបមកពីដកដំឡូងមិញហ្នឹង ។

សុវណ្ណៈ ក្រោយពីធ្វើស្រែចម្ការមានធ្វើអីផ្សេងទៀតទេ?

វ៉នៈ មានធ្វើអីទេ មានតែនៅផ្ទះចិញ្ចឹមសត្វអីហ្នឹង ។

សុវណ្ណៈ ភាគច្រើនធ្វើស្រែឬមួយធ្វើចម្ការ?

វ៉ន: ធ្វើស្រែផងធ្វើចម្ការផង ខែនេះធ្វើចម្ការ ។

សុវណ្ណ: ចម្ការដាំអីគេ?

វ៉ន: ដាំដំឡូងមី ។

សុវណ្ណ: ដំឡូងខែហ្នឹងលក់បានថ្លៃទេ?

វ៉ន: ពុថាមួយគីឡូបាន៦០០ ។

សុវណ្ណ: មានខាងណាមកទិញ?

វ៉ន: ដឹងខាងណាផង ឃើញខាងត្រពាំងប្រាសាទមកទិញ តែខាងនេះមានទាន់ពីណាចូលទិញទេ យើងទើបធ្វើ ។

សុវណ្ណ: ចឹងឆ្នាំទៅៗយើងលក់បានថ្លៃទេ?

វ៉ន: បានមួយគីឡូ៥០០ឬ៦០០ ។

សុវណ្ណ: ចឹងឆ្នាំនេះពុថាបានថ្លៃបន្តិច?

វ៉ន: ឆ្នាំនេះពុថាបាន៦៦០ ។

សុវណ្ណ: ពូជយើងយកមកពីណាវិញ?

វ៉ន: ដឹងគេយកមកពីណាឃើញគេដឹកឡានមកលក់ ។

សុវណ្ណ: មិនមែនយើងទៅទិញពីក្រុមហ៊ុនទេ?

វ៉ន: អត់ទេ គេយកមកលក់ ។

សុវណ្ណ: គេមានឲ្យពូជចឹងទៅតែយើងយកលក់ឲ្យគេមានទេ?

វ៉ន: អត់ទេ គេដឹកឡានមកយើងទៅទិញតែម្ដង ។

សុវណ្ណ: ចឹងភូមិនេះគេហៅភូមិអីគេ?

វ៉ន: ភូមិទួលប្រាសាទ ។

សុវណ្ណ: ឃុំ?

វ៉ន: ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ។

សុវណ្ណ: ចឹងស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ?

វ៉ន: ចាស ។

សុវណ្ណ: ចឹងយ៉ាងម៉េចបានជាគេដាក់ឃុំទំនប់ដាច់ចឹង?

វ៉ន: ទេ មិនដឹងជាយ៉ាងម៉េច ខ្ញុំមកពីហ្នឹងមកគេដាក់ចឹងតែម្ដង គេហៅចឹង មានទំនប់មួយវាដាច់ ចឹងគេហៅទំនប់ដាច់ចឹង ។

សុវណ្ណ: ទំនប់ហ្នឹងពីណាជាអ្នកកសាង?

រ៉ន: ទេ កាលហ្នឹងមិនដឹងជាពីណាកសាងទេ ខាងពួកខ្មែរក្រហមនិងឯង ខ្ញុំពួកខ្ញុំមកនៅនេះខ្ញុំមក មិនទាន់ដែលហ្នឹង គេអ្នកនៅមុនមួយគទៀត ។

សុវណ្ណ: គ្រួសារមីងឈ្មោះអីគេ?

រ៉ន: ប្តីខ្ញុំស្លាប់២០ឆ្នាំជាងហើយ ។

សុវណ្ណ: គាត់ឈ្មោះអីគេ?

រ៉ន: ឈ្មោះ អុន ។

សុវណ្ណ: គាត់ឈ្មោះអី អុន ត្រកូល?

រ៉ន: គាត់ស្លាប់យូរហើយសម័យហ្នឹងមិនបានចាំដែលហ្នឹង ។

សុវណ្ណ: គាត់ពីមុនធ្វើអីគេ?

រ៉ន: គាត់ធ្វើនៅក្នុងខ្មែរក្រហមដែរ ។

សុវណ្ណ: ចឹងអតីតទាហានដែរ?

រ៉ន: ចាស ។

សុវណ្ណ: ទាហានខាងកងពលណា?

រ៉ន: ៨០១ ។

សុវណ្ណ: ពីណាគ្រប់គ្រង៨០១?

រ៉ន: តា០៥ហ្នឹង តាសារឿន ហ្នឹង ។

សុវណ្ណ: ម៉េចបានមីងស្គាល់គាត់?

រ៉ន: គាត់ជាអ្នកដឹកនាំជំនាន់ហ្នឹងមេធំកងពល ។

សុវណ្ណ: មីងខស្សាហ៍ជួបតា០៥ទេ?

រ៉ន: ខស្សាហ៍ជួបបើនៅជាមួយគាត់ហើយ ។

សុវណ្ណ: គាត់ជាមនុស្សយ៉ាងម៉េចដែរ?

រ៉ន: កាលសម័យនោះមិនដឹងជាថា យ៉ាងម៉េច ឃើញគាត់ល្អខ្ញុំថាល្អ យើងនៅជាមួយគាត់មិន មានដលរមាស់អីផង ។

សុវណ្ណ: ការដឹកនាំរបស់គាត់យ៉ាងម៉េចដែរ នៅក្រោមការគ្រប់គ្រងរបស់គាត់ពេលហ្នឹង?

រ៉ន: ពេលហ្នឹងនៅក្នុងការគ្រប់គ្រងរបស់គាត់ ពេលហ្នឹងឃើញគាត់ដឹកនាំយើងល្អចឹងចេះតែទៅ តាមគាត់ធ្វើតាមគាត់មិនដែលឃើញគាត់កើតអីផង ។

សុវណ្ណ: គាត់មានស្រុកកំណើតនៅណាតា០៥ហ្នឹង?

រ៉ន: នៅកំពត ។

សុវណ្ណៈ	ម៉េចបានដឹងថានៅកំពត?
វ៉ន៖	ដឹងបើគាត់និយាយ ប្រពន្ធគាត់និយាយ ។
សុវណ្ណៈ	ប្រពន្ធគាត់ឈ្មោះអីគេ?
វ៉ន៖	ប្រពន្ធគាត់ឈ្មោះ យាយ នន ។
សុវណ្ណៈ	យាយ នន ហ្នឹងគាត់មកពីខាងណាវិញ?
វ៉ន៖	គាត់នៅស្រុកគាត់ហ្នឹងដែរ ខាងកំពតហ្នឹងដែលហ្នឹង ។
សុវណ្ណៈ	តែកំពត មានដឹងថាស្រុកណាទេ?
វ៉ន៖	ខ្ញុំមិនដឹងផង ។
សុវណ្ណៈ	ចឹងមីងមានស្រុកកំណើតនៅណា?
វ៉ន៖	ខ្ញុំនៅតាកែវ ។
សុវណ្ណៈ	នៅភូមិអីគេ?
វ៉ន៖	ភូមិស្គុល ។
សុវណ្ណៈ	ឃុំ?
វ៉ន៖	នៅឃុំស្មោង ។
សុវណ្ណៈ	ស្រុក?
វ៉ន៖	ឥឡូវគេដាក់កោះអណ្ដែត ។
សុវណ្ណៈ	ចឹងពីមុន?
វ៉ន៖	កាលពីមុនឃុំស្មោងគេដាក់ស្រុកទ្រាំង ខេត្តតាកែវ ។
សុវណ្ណៈ	ចឹងកាលពីមុនគេដាក់ស្រុក១០៨?
វ៉ន៖	កាលមុនគេដាក់ស្រុក១០៨ ។
សុវណ្ណៈ	ចឹងស្រុក១០៨ហ្នឹង យើងនិយាយក្នុងរបបបីឆ្នាំទេ?
វ៉ន៖	ចាស ។
សុវណ្ណៈ	ចឹងមុនរបបបីឆ្នាំគេហៅស្រុកអីគេ?
វ៉ន៖	គេដាក់ស្រុកទ្រាំង ខេត្តតាកែវ ហ្នឹង ។
សុវណ្ណៈ	ចឹងស្រុកទ្រាំង?
វ៉ន៖	ចាស ។
សុវណ្ណៈ	មីងសព្វថ្ងៃមានកូនប៉ុន្មាននាក់?
វ៉ន៖	ខ្ញុំមានកូនបួននាក់ ។

សុវណ្ណៈ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

រ៉នៈ ប្រុស១ស្រី៣ ។

សុវណ្ណៈ មានគ្រួសារអស់ហើយនៅ?

រ៉នៈ មានគ្រួសារអស់ហើយ ។

សុវណ្ណៈ ប្ដីមីងគាត់ស្លាប់នៅឆ្នាំណា?

រ៉នៈ មើលឆ្នាំណាទេ មើលឆ្នាំ៩២ ។

សុវណ្ណៈ ចឹងស្លាប់ឆ្នាំ៩២?

រ៉នៈ ចាស ។

សុវណ្ណៈ គាត់ស្លាប់ដោយសារអីគេ?

រ៉នៈ ស្លាប់ដោយសារជាន់មីន ។

សុវណ្ណៈ ជាន់មីនពេលទៅវាយនៅខាងណា?

រ៉នៈ ពេលគាត់ដើរទៅរកស៊ី ។

សុវណ្ណៈ គាត់ដើររកស៊ីយ៉ាងម៉េច ពេលឆ្នាំ៩២យើងនៅវាយជាមួយរដ្ឋាភិបាលតើ?

រ៉នៈ ចាស!គាត់ឃើញគេរកចេះតែទៅជាមួយគេទៅ ។

សុវណ្ណៈ ទៅណាកាលហ្នឹង?

រ៉នៈ ទៅខាងអូរត្រាវ ។

សុវណ្ណៈ គាត់ទៅធ្វើអីគេនៅអូរត្រាវ?

រ៉នៈ គាត់បោចផ្ដៅ ។

សុវណ្ណៈ ចឹងកាលហ្នឹងគាត់ឈប់ធ្វើទាហានហើយនៅ?

រ៉នៈ នៅ ។

សុវណ្ណៈ ចឹងនៅធ្វើទាហាននៅឡើយទេ?

រ៉នៈ ចាស!ដូចថាគេឲ្យនៅខាងក្រោយនៅចឹងម្ដងៗចេះតែដើរទៅ ។

សុវណ្ណៈ មីងមានបងប្អូនប៉ុន្មាននាក់?

រ៉នៈ បងប្អូនខ្ញុំរាល់ថ្ងៃមាន៧នាក់ ។

សុវណ្ណៈ មានប្រុសប៉ុន្មានស្រីប៉ុន្មាន?

រ៉នៈ ប្រុស៣ស្រី៤ ។

សុវណ្ណៈ មីងកូនទីប៉ុន្មាន?

រ៉នៈ ខ្ញុំទី១ ។

សុវណ្ណៈ ចឹងកាលពីមីងរៀបការហ្នឹង ការនៅឆ្នាំណា ការជាមួយពូអុន នោះ?

វ៉ន: មិនដឹងជាឆ្នាំណាទេ ឆ្នាំ៨០ប៉ុន្មាន អើឆ្នាំ៧៦ ។

សុវណ្ណៈ ការនៅក្នុងរបបបីឆ្នាំ?

វ៉ន: ចាស!កាលហ្នឹងយើងរត់ទៅនៅអូរត្រាវ ស្រុកថៃ ។

សុវណ្ណៈ ចឹងការនៅណា?

វ៉ន: បើនិយាយរឿងការ ប្ដីខ្ញុំមានពីរ យកប្ដីមុននោះបានកូនមួយ ។

សុវណ្ណៈ ចឹងនិយាយពីដំបូង?

វ៉ន: ឥឡូវមិនបាច់ទេ ខ្ញុំនិយាយតែមួយហ្នឹង ។

សុវណ្ណៈ ចឹងពូអុន គ្រួសារដំបូង?

វ៉ន: ទី២ ទី១បានកូន១ទី២បានកូន៣ ។

សុវណ្ណៈ ចឹងពូអុន ហ្នឹងគាត់ការឆ្នាំ៧៦?

វ៉ន: ហ្នឹងហើយដាក់តែ៧៦ហ្នឹងទៅ ។

សុវណ្ណៈ ការដំបូង៧៦?

វ៉ន: ចាស ។

សុវណ្ណៈ តែដំបូងមិនមែនពូអុន ទេ?

វ៉ន: ចាស!ដាក់៧៦ចឹងទៅ ។

សុវណ្ណៈ ចឹងគ្រួសារដំបូងគាត់មានឈ្មោះអីគេ?

វ៉ន: ឈ្មោះ នី ។

សុវណ្ណៈ ចឹងការឆ្នាំណា៧៦?

វ៉ន: ឆ្នាំ៨៣ ។

សុវណ្ណៈ មានតែ៨៦រត់ទៅភ្នំ ចឹង៨៦ពូអុន ត្រូវទេ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងការនៅលើភ្នំហ្នឹង?

វ៉ន: ចាស!នៅខ្មែរក្រហមយើងហ្នឹង ។

សុវណ្ណៈ ការនៅលើភ្នំដងរែកហ្នឹង?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងពូអុន ហ្នឹងគ្រួសារក្រោយទេ?

វ៉ន: ចាស!មួយនោះបានកូនមួយ ។

សុវណ្ណៈ	ពូអុន បានកូន១?

វ៉ន: អត់ទេ ប្ដីខ្ញុំឈ្មោះ នី ហ្នឹងបានកូន១ ក្រោយមកបាន៣ ។

សុវណ្ណៈ បាន១ស្រីប្រុសដំបូង?

វ៉ន: ប្រុស ។

សុវណ្ណៈ ការជាមួយពូនី ការឆ្នាំណា?

វ៉ន: មិនដឹងជាឆ្នាំណាទេ ភ្លេចអស់ហើយ ដាក់តែមួយហ្នឹងទៅ ។

សុវណ្ណៈ ចឹងសព្វថ្ងៃហ្នឹងមានដែលបានជួបបងប្អូនទេ ពេលមកនៅហ្នឹង មីងនៅតែឯងតើ?

វ៉ន: ឥឡូវយកប្អូនខ្ញុំមកនៅពីរនាក់បានបីនាក់ ។

សុវណ្ណៈ ចឹងមីងបានជួបបងប្អូនដំបូងជួបឆ្នាំណា?

វ៉ន: ឆ្នាំណាមួយសារទៅជាមួយអាចេក ហ្នឹងមិនដឹងជាឆ្នាំប៉ុន្មានទេ ។

សុវណ្ណៈ យើងសមាហរណ៍កម្មហើយប្ដូរមួយយ៉ាងម៉េច?

វ៉ន: ចាស!សមាហរណ៍កម្មហើយ ។

សុវណ្ណៈ ហើយបានប៉ុន្មានខែប៉ុន្មានឆ្នាំបានយើងទៅលេង យើងទៅលេងបងប្អូនមុនប្ដូបងប្អូនមកលេងយើងមុន?

វ៉ន: ខ្ញុំទៅ ខ្ញុំសុខចិត្តដើរទៅជិះឡាននៅសៀមរាបនោះ បំណាច់ថានឹកបងប្អូនហើយ ដើរពីនេះទៅ ។

សុវណ្ណៈ ឆ្នាំណាកាលហ្នឹងមីង មាននៅចាំទេ សមាហរណ៍កម្មហើយបានប៉ុន្មានខែប៉ុន្មានឆ្នាំ ព្រោះសមាហរណ៍កម្មយើងឆ្នាំ៩៨?

វ៉ន: ចាស ។

សុវណ្ណៈ ចុង៩៨មីង?

វ៉ន: ចុង៩៨ហ្នឹងឯង មិនបានយូរទៅលេង កាលហ្នឹងសមាហរណ៍កម្មហើយបានប្រហែលជា១ខែ២ខែទៅលេង ។

សុវណ្ណៈ ចឹងពេលទៅលេងយើងបានជួបបងប្អូនដំបូងយើងមានអារម្មណ៍យ៉ាងម៉េចដែរ?

វ៉ន: មានអារម្មណ៍សប្បាយអរ បើបែកយូរហើយតាំងពីឆ្នាំ៧៣ ។

សុវណ្ណៈ ចឹងពេលជុំគ្នាយើងនិយាយជាមួយបងប្អូនយ៉ាងម៉េច ដំបូងៗចឹង?

វ៉ន: ជុំគ្នាមានយើងនិយាយពីប្រវត្តិយើងនៅក្នុងព្រៃអីហ្នឹង ម៉ែឪយំ ម៉ែខ្ញុំឪខ្ញុំនឹក ។

សុវណ្ណៈ ចឹងពេលទៅស្គាល់ឪពុកម្ដាយបងប្អូនស្គាល់ដែរ?

វ៉ន: អត់ស្គាល់ទេ ម៉ែខ្ញុំមើលខ្ញុំមិនចង់ស្គាល់ដែរ ។

សុវណ្ណៈ ព្រោះយើងទៅកាលហ្នឹងនៅក្មេងៗ?

វ៉ន: ចាស ។

សុវណ្ណៈ ដល់ពេលយើងទៅវិញរាងចំណាស់ដែលហើយដល់ពេលនេះអត់ស្គាល់គ្នាទេ ចឹងធ្វើយ៉ាងម៉េចបានស្គាល់គ្នាទៅ?

វ៉ន: ខ្ញុំទៅឪខ្ញុំកាលមួយសារអ៊ុនគាត់ហ្នឹងគាត់មកលេង គាត់សុខចិត្តមកតាមរយៈលំបាកយ៉ាងម៉េចក៏មក គាត់ស្ដាត់មករកជួបខ្ញុំ ដល់ចឹងខ្ញុំបានស្គាល់ឪខ្ញុំទៅ ដឹងថាមែឪខ្ញុំនៅខ្ញុំទៅលេង គាត់មកជិះរយៈតាមឡានដឹកឈើអីហ្នឹងមកដល់ហ្នឹង កាលហ្នឹងមានថៃចូលមកដឹកឈើអី គាត់ជិះមកជួបខ្ញុំនៅត្រង់ហ្នឹង ។

សុវណ្ណៈ ឆ្នាំណាកាលហ្នឹង?

វ៉ន: កាលហ្នឹងឆ្នាំ៩២ហើយឪខ្ញុំមក ។

សុវណ្ណៈ ចុង៩២ហើយ៩៣ឪពុកមីងមក?

វ៉ន: ចាស ។

សុវណ្ណៈ ឪពុកមីងឈ្មោះអីគេ?

វ៉ន: ឈ្មោះ ទិត ជា ។

សុវណ្ណៈ ចឹងមីងម៉េចបានជាខុសត្រកូលឪពុក?

វ៉ន: ខ្ញុំចេះតែដាក់ៗទៅ ។

សុវណ្ណៈ ចឹងឈ្មោះមីងពិតប្រាកដអី?

វ៉ន: ខ្ញុំនៅផ្ទះខ្ញុំគេហៅខ្ញុំឈ្មោះ ណេន ។

សុវណ្ណៈ ចឹងឈ្មោះ ឃុន វ៉ន នោះយ៉ាងម៉េចទៅ?

វ៉ន: ខ្ញុំទើបដាក់ឈ្មោះថ្មី ។

សុវណ្ណៈ ចឹងឈ្មោះពីមុន?

វ៉ន: ឈ្មោះពីមុនឈ្មោះ ណេន ។

សុវណ្ណៈ អីគេណេន?

វ៉ន: ខ្ញុំគ្មានដែលដាក់ស្អីទេ ខ្ញុំមកព្រៃដាក់ចឹងតែម្ដង ។

សុវណ្ណៈ ចឹងកាលហ្នឹងឪពុកមីងគាត់ធ្វើអីគេ កាលមីងនៅក្មេងៗឪពុកធ្វើអីគេ?

វ៉ន: មានធ្វើអី ធ្វើស្រែចម្ការ ស្រុកស្រែធ្វើតែស្រែហ្នឹង ។

សុវណ្ណៈ ចឹងឥឡូវ?

វ៉ន: ឥឡូវគាត់ស្លាប់ទើបមួយឆ្នាំ ។

សុវណ្ណៈ ចឹងទើបស្លាប់មួយឆ្នាំពីរឆ្នាំនេះទេ?

វ៉ន: ចាស!ទាំងឪទាំងម៉ែស្លាប់អស់ ។

សុវណ្ណៈ ចឹងម្ដាយឈ្មោះអីគេ?

វ៉ន: ម្ដាយខ្ញុំឈ្មោះ ឈយ សឿង ។

សុវណ្ណៈ ចឹងគាត់ទើបតែខូចបានមួយឆ្នាំពីរឆ្នាំនេះដែលទេ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងនៅក្មេង មីងឈប់រៀនត្រឹមថ្នាក់ទីប៉ុន្មានដែរ?

វ៉ន: ខ្ញុំគ្មានបានរៀនទេ ខ្ញុំបងគេបង្អស់ពរតែប្អូនឡើងផ្ដេចផ្ដេះអស់ហើយបានតែប្អូន ។

សុវណ្ណៈ ម៉េចបានជាមិនបានរៀនចឹង?

វ៉ន: ម៉ែខ្ញុំទីទាល់ក្រ ដល់ចឹងពិបាកបើខ្ញុំទៅរៀន អត់មានអ្នកធ្វើស្រែអី ខ្ញុំសូមចូលរៀនម៉ែខ្ញុំពិបាកអត់ឲ្យចូលរៀនទេ តែប្អូនខ្ញុំចេះអក្សរទាំងអស់អត់តែខ្ញុំមួយ ។

សុវណ្ណៈ ពេលមីងសុំចូលរៀនម្ដាយមីងថាយ៉ាងម៉េច?

វ៉ន: គាត់ថា មិនមានអ្នកមើលប្អូន ។

សុវណ្ណៈ ចឹងមានបានចូលរៀនខ្លះទេ បានមួយឆ្នាំពីរឆ្នាំទេ?

វ៉ន: រៀនមិនបានកន្លះឆ្នាំផង គេបង្រៀនអក្ខរកម្មតាមផ្ទះ ។

សុវណ្ណៈ ចឹងបានរៀនអក្ខរកម្មតាមផ្ទះដែរ?

វ៉ន: ចាស ។

សុវណ្ណៈ តែមិនបានចូលសាលាទេ?

វ៉ន: អត់ទេ ។

សុវណ្ណៈ រៀនអក្ខរកម្មតាមផ្ទះហ្នឹងបានប្រហែលជាប៉ុន្មានខែប៉ុន្មានឆ្នាំ?

វ៉ន: រៀនមិនបានមួយខែផង បានមកតាមព្រៃ ។

សុវណ្ណៈ ខ្ញុំចង់និយាយជំនាន់សីហនុ កាលនៅក្មេង?

វ៉ន: ចាស!នៅក្មេងហ្នឹងរៀនចេះអានរួចហ្នឹង ដល់មកខ្មែរក្រហមហ្នឹងដូចថារៀនពេលម៉ោងសម្រាកចឹងគេចេះតែបង្រៀនចឹងទៅ ចឹងបានត្រឹមចេះមើលនិងសរសេរបានតិចៗ ។

សុវណ្ណៈ ចឹងខ្ញុំចង់និយាយថា ពេលដែលមីងនៅក្មេង មីងអត់បានចូលសាលារៀនទេ ត្រូវទេ?

វ៉ន: ចាស ។

សុវណ្ណៈ តែយើងបានរៀនអក្ខរកម្មតាមផ្ទះ?

វ៉ន: ហ្នឹងហើយបានរៀនបានបន្តិចហ្នឹង ។

សុវណ្ណៈ រៀនតិចហ្នឹងរៀនបានត្រឹមណា?

វ៉នៈ រៀនបានត្រឹមចេះអានរួច កាលហ្នឹងមើលតិចៗ ។

សុវណ្ណៈ ហើយពីណាគេអ្នកបង្រៀនកាលហ្នឹង?

វ៉នៈ កាលហ្នឹងគ្រូហ្នឹងត្រូវជាអ៊ំខ្ញុំ ឈ្មោះ ស្តើង ។

សុវណ្ណៈ ឈ្មោះ អីគេស្តើង?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងមានអីផ្សេងទៀតដែលធ្វើឲ្យមីងមិនបានចូលរៀន មីងជាប់រវល់ការងារជួយឪពុកម្តាយកាល?

វ៉នៈ ចាស ។

សុវណ្ណៈ មានស្អីទៀតទេ?

វ៉នៈ មានអីទេ មាននៅមើលប្អូនអីហ្នឹង ។

សុវណ្ណៈ ចឹងជីវភាពកាលមីងនៅក្មេងយ៉ាងម៉េចដែលមីង គ្រប់គ្រាន់ឬមួយមិនគ្រប់គ្រាន់ទេ?

វ៉នៈ ខ្វះខាតដែលហ្នឹង ម៉ែឪខ្ញុំ ហូបស្រូវមិនគ្រប់ចឹងទៅណាខ្វះត្រឹមពីរបីខែ បានដល់ស្រូវទុំចឹងដល់ចឹងខ្ចីរគេចឹងទៅណា ។

សុវណ្ណៈ ចឹងស្រុកទេសយ៉ាងម៉េចដែលពេលមីងនៅក្មេងៗ បានសុខសប្បាយទេ?

វ៉នៈ កាលហ្នឹងដូចជាមិនឃើញកើតអី ។

សុវណ្ណៈ ចឹងពេលរដ្ឋប្រហារហើយ?

វ៉នៈ រដ្ឋប្រហារហើយពិបាក ។

សុវណ្ណៈ ពិបាកយ៉ាងម៉េចទៅ?

វ៉នៈ ពិបាករត់បន្តិចទៅនៅភូមិនេះ ជម្លៀសចេញពីភូមិចឹងទៅ ។

សុវណ្ណៈ ចឹងមានឃើញចលនាតស៊ូគេចូលមកក្នុងភូមិមកឃោសនាឲ្យប្រជាជនចូលរួមជាមួយគេហើយនៅកាលហ្នឹង?

វ៉នៈ មិនទាន់ឃើញមានឃោសនាអី ឃើញមានកងឈ្លបកងអីហ្នឹងនៅក្នុងភូមិអីចឹង ។

សុវណ្ណៈ ចឹងមុនរដ្ឋប្រហារហ្នឹងមានទាហាន លន់ នល់ មកគ្រប់គ្រងស្រុកភូមិទេកាលហ្នឹង?

វ៉នៈ ចាស!មានមកចឹងដល់ហើយមានឈ្លប ខាងហ្នឹងមានគេបង្កើតឈ្លបហ្នឹងខាងណា ។

សុវណ្ណៈ ខាងយើងតស៊ូនេះទេ?

វ៉នៈ ចាស ។

សុវណ្ណៈ តែខ្ញុំចង់និយាយថា ការគ្រប់គ្រងរបស់ លន់ នល់ ហ្នឹងយ៉ាងម៉េចដែលមីង ទាហានលន់ នល់ គ្រប់គ្រងក្នុងភូមិយើងគេមានធ្វើបាបប្រជាជនទេ ពេលហ្នឹង?

រ៉ន: កាលពេលហ្នឹងមិនឃើញធ្វើអីដែរ ។

សុវណ្ណៈ កាលហ្នឹងមីងនៅអាយុប៉ុន្មាន?

រ៉ន: កាលហ្នឹងអាយុប៉ុន្មានទេ ខ្ញុំនៅឃ្វាលគោនៅឡើយ ។

សុវណ្ណៈ មីងមានសង្កេតឃើញ ពេលទាហាន លន់ នល់ គ្រប់គ្រងក្នុងស្រុកភូមិហ្នឹង?

រ៉ន: ដល់ពេលរដ្ឋប្រហារហើយនេះ ។

សុវណ្ណៈ បាទ ។

រ៉ន: ហ្នឹងពិបាកណាស់ ។

សុវណ្ណៈ ចឹងឃើញមានចលនាចូលមកនៅក្នុងភូមិបណ្ដើរៗនៅ ឃើញមានទាហានចុះឡើងមានទេ?

រ៉ន: ឃើញតើ វាយគ្នាក្នុងភូមិខ្ញុំ គេកាត់កពួកទាហាន ពួកឈ្លបពួកអី ពិបាក កាលហ្នឹងមហាពិបាកនោះ ។

សុវណ្ណៈ ពិបាកយ៉ាងម៉េចខាងណាវាយជាមួយខាងណា?

រ៉ន: ទាហានហ្នឹង ទាហានអីកាលយើងសម័យហ្នឹង ពួកទាហាននៅតាមបន្ទាយតាមអីនៅផ្សារកំពង់ជ្រែអីហ្នឹងមក ដល់បង្កើតឈ្លបអីវាយគ្នាក្នុងភូមិហ្នឹង ។

សុវណ្ណៈ ចឹងមីងបានចូលបដិវត្តជាមួយគេទេ?

រ៉ន: ទើបចូលក្នុងឆ្នាំ៧៣ ខែ៣ ។

សុវណ្ណៈ ចឹង៧៣ខែ៣?

រ៉ន: ចាស! រត់មកនៅក្នុងព្រៃទៅបានចូលទ័ពជាមួយគេ ។

សុវណ្ណៈ ចឹងមានមូលហេតុអីបានជាចូលបដិវត្ត?

រ៉ន: វាពិបាកពេក នៅក្នុងភូមិហ្នឹងរត់ចុះរត់ឡើង ម្លោះហើយខ្ញុំចូលនៅក្នុងព្រៃជាមួយគេតស៊ូនិងគេទៅ គេរើសចូលខាងទ័ពក៏ចូលជាមួយគេ ។

សុវណ្ណៈ តែមីងចិត្តចង់ចូលតស៊ូជាមួយខាងខ្មែរក្រហម មីងគិតថាមានគោលបំណងអីមានដែនការចូលរួមជាមួយគេអត់ឬយើងចេះតែចូលតាមគេក្នុងភូមិ?

រ៉ន: ឃើញគេមក កាលហ្នឹងចូលនិងគេទៅដល់ហើយហ្នឹងក៏ចេះតែមកតាមគេតាមឯងហ្នឹងធ្វើរហូតមក ។

សុវណ្ណៈ ចឹងមីងមានគិតថា ចូលតស៊ូដើម្បីរំដោះជាតិ រំដោះសម្ដេចដើម្បីមកគ្រប់គ្រងប្រទេសវិញ មានគិតចឹងទេ?

វ៉ន:	កាលហ្នឹងគ្មានទាន់នឹកឃើញអីទេ យើងចូលមក ចូលទ័ពហ្នឹងចេះតែចូលមក មកកាន់កាំភ្លើងជាមួយគេទៅ ។

សុវណ្ណៈ	ចឹងតាមគេតាមឯងទៅ?

វ៉ន:	ចាស!ដល់ពេលចូលទៅបានដឹងថា វាលំបាកចេះចុះ ។

សុវណ្ណៈ	លំបាកយ៉ាងម៉េច?

វ៉ន:	ចុះបើចូលទ័ពអីយើងវាយគ្នាទៅ ដល់ពេលនេះទៅមិនខ្លាចស្លាប់ចេះតែនឹកឃើញហើយ ។

សុវណ្ណៈ	កាលហ្នឹងយើងចូលទៅខាងណាវិញ ពេលចូលបដិវត្ត?

វ៉ន:	ខ្ញុំចូលហើយមកធ្វើទ័ពហើយ គេបញ្ជូនទៅតាកែវ ទៅតាកែវហើយទៅខាងភ្នំដិន រួចពីភ្នំដិនគេថាវាយភ្នំពេញ ដល់បែកភ្នំពេញគេយកខ្ញុំមកដាក់នៅភ្នំពេញ ។

សុវណ្ណៈ	ចឹងខ្ញុំចង់ដឹងរឿងឆ្នាំ៧៣បន្តិចសិន?

វ៉ន:	ចាស ។

សុវណ្ណៈ	ចូលដំបូងចូលធ្វើទ័ពគេឲ្យយើងទៅឈរជើងនៅខាងណា?

វ៉ន:	ឲ្យនៅខាងតាកែវ ។

សុវណ្ណៈ	ទៅខាងស្រុកណាកាលហ្នឹង?

វ៉ន:	កាលហ្នឹងមករៀននៅខាងស្រុក១០៥ ។

សុវណ្ណៈ	ចឹង១០៥ហ្នឹងនៅជិតនៅស្រុកណាក្នុងខេត្តតាកែវ?

វ៉ន:	ស្រុកត្រាំកក់ គេហៅស្រុក១០៥ហ្នឹង ។

សុវណ្ណៈ	មន្ទីរ “ខ” ប៉ុន្មានមីង?

វ៉ន:	មិនដឹងជាខប៉ុន្មាន ។

សុវណ្ណៈ	ចឹង១០៥ស្រុកត្រាំកក់?

វ៉ន:	ចាស ។

សុវណ្ណៈ	ចឹងពេលហ្នឹងយើងនៅក្នុងព្រៃឬមួយយើងនៅក្នុងភូមិ?

វ៉ន:	នៅក្នុងភូមិដូចជានៅខាងជើងតាកែវ ប្រជាជនជម្លៀសចេញអស់យើងនៅតាមផ្ទះហ្នឹង ។

សុវណ្ណៈ	ចឹងកាលចូលដំបូងគេឲ្យយើងរៀនទ្រឹស្តីប៉ុន្មានខែទៅ?

វ៉ន:	ហាត់មួយខែ ។

សុវណ្ណៈ	មួយខែហ្នឹងហាត់រៀនអីគេ?

វ៉ន:	គេរៀនឲ្យយើងកាន់កាំភ្លើង ចេះបាញ់អីចឹងទៅ រៀននយោបាយឲ្យយើងចេះដឹងយល់អីហ្នឹង ។

សុវណ្ណៈ ចឹងហាត់រៀនបានតែមួយខែគេឲ្យយើងទៅសមរភូមិតែម្តង?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងអត់មានបានរៀន៣ខែ៦ខែអីទេ?

វ៉ន: អត់ទេ ។

សុវណ្ណៈ ចឹងការហាត់រៀនហ្នឹងវាពិបាកឬមិនពិបាកទេ កាលហ្នឹងមីង?

វ៉ន: កាលហ្នឹងគេហៅមន្ទីរលុតដុំពិបាកដែរ ការហូបចុកខ្វះខាតដែលហ្នឹង គេឲ្យហូបក្នុងនាមសន្សំសំចៃ ។

សុវណ្ណៈ ចឹងដល់យើងពិបាកចឹងយើងមានចង់ឈប់ទេ?

វ៉ន: អត់មានចង់ឈប់ទេ ដូចថាមិនចង់ឈប់ផង ។

សុវណ្ណៈ ម៉េចបានមីងមិនចង់ឈប់ ក្រែងយើងធ្លាប់ស្រួលខ្លះដល់យើងទៅលំបាកចឹងម៉េចទៅ?

វ៉ន: កាលហ្នឹងចេះតែនឹកឃើញគេយ៉ាងម៉េច យើងយ៉ាងម៉េច ។

សុវណ្ណៈ ចឹងតាំងពីឆ្នាំ៧៣មក មីងបែកពីគ្រួសារបែកពីបងប្អូនហើយ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងបែកមករហូតមកនៅជុំជាមួយទ័ពគេទៅ?

វ៉ន: ហ្នឹងហើយ ។

សុវណ្ណៈ ចឹងហាត់បានមួយខែគេបញ្ជូនទៅវាយនៅខាងណា?

វ៉ន: ខាងតាកែវ ។

សុវណ្ណៈ ទៅវាយខាងភ្នំដិនតាកែវ?

វ៉ន: តាហើយបានផ្លាស់ចេញពីតាកែវ នៅខាងភ្នំដិន ទៅនៅភ្នំដិនហ្នឹង ។

សុវណ្ណៈ មីងឈប់សិន ចឹងយើងហាត់រៀនបានមួយខែ ក្រោយមកគេឲ្យយើងឡើងវាយនៅសមរភូមិ?

វ៉ន: ចាស ។

សុវណ្ណៈ ទៅសមរភូមិដំបូងទៅសមរភូមិណា?

វ៉ន: តាកែវ ។

សុវណ្ណៈ តាកែវ តែនៅស្រុកណា?

វ៉ន: ខាងជើងតាកែវហ្នឹងមិនដឹងជាម្តុំណា ខ្ញុំមិនសូវស្គាល់ដែរ ។

សុវណ្ណៈ ចឹងក្រោយមកនៅសមរភូមិនៅភ្នំដិនទៀត?

វ៉ន: ចាស ។

សុវណ្ណៈ ទៅខាងភ្នំដិនទៅវាយជាមួយខាងណា?

រ៉ន: គេឲ្យទៅចិនទៅ គេឲ្យទៅដើរធ្វើការល្បាត ។

សុវណ្ណៈ ចឹងអត់មានបានវាយអីទេ?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងគ្រាន់ល្បាតការពារតាមព្រំដែនទៅ?

រ៉ន: ចាស ។

សុវណ្ណៈ មានបានឡើងទៅសមរភូមិខាងណាខ្លះទេ?

រ៉ន: អត់ទេ បើបងគាត់បានឡើងទៅយាមខាងនោះ ខ្ញុំគេឲ្យនៅយាមកន្លែងមន្ទីរ ។

សុវណ្ណៈ ចឹងមីងនៅប្រចាំការរហូតទៅ?

រ៉ន: ចាស ។

សុវណ្ណៈ ចឹងចេញពី១០៥ទៅខាងណាវិញ ពេលហ្នឹង មុនដំបូងនៅត្រាំកក់?

រ៉ន: ហ្នឹងហើយចេញពីមន្ទីរហ្នឹងមកតាកែវ ។

សុវណ្ណៈ ចឹងក្រោយមកទៅភ្នំដិន?

រ៉ន: ចាស!គេឲ្យផ្លាស់ទៅខាងហ្នឹងម្តង ។

សុវណ្ណៈ ពេលទៅភ្នំដិនទៅឆ្នាំណាកាលហ្នឹង?

រ៉ន: នៅខាងជើងតាកែវហ្នឹង មិនបានមួយឆ្នាំផង គេឲ្យទៅហ្នឹងទៀត ។

សុវណ្ណៈ ទៅភ្នំដិនហ្នឹង?

រ៉ន: ចាស ។

សុវណ្ណៈ ទៅឆ្នាំណាកាលហ្នឹង?

រ៉ន: បងយើងទៅភ្នំដិនឆ្នាំណា «អ្នកជិតខាងនិយាយថាឆ្នាំ៧៣» ។

សុវណ្ណៈ ៧៣ដដែល ចឹងចុង៧៣មីង?

រ៉ន: ចាស!ចុងហើយ ខែប្រូតហើយ ។

សុវណ្ណៈ ចឹងនៅឈរជើងរហូតដល់ពេលគេវាយបែកភ្នំពេញ?

រ៉ន: នៅភ្នំពេញហ្នឹងមិនទាន់បែកផងគេគេឲ្យទៅ បងកាលហ្នឹងបែកហើយនៅ«អ្នកជិតខាងនិយាយថា បែកហើយ»ហ្នឹងហើយបានគេឲ្យដំណឹងគេឲ្យទៅគេឲ្យទៅរតនគិរីទៀត ។

សុវណ្ណៈ ចឹងក្រោយមកគេដឹកទៅភ្នំពេញ?

រ៉ន: ភ្នំពេញ ។

សុវណ្ណៈ ចឹងកាលហ្នឹងពីណាគេមកយកទៅ?

វ៉ន៖ មិនដឹងជាពីណាឃើញតែឡានគេមក ច្រើនណាស់មកយក ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងមានដឹងថាពីណាគេឲ្យមកយកទេ?

វ៉ន៖ ទេ ដឹងថាអង្គការគេឲ្យមកដឹកអីទៅ មិនដឹងជាខាងណាបើយើងមិនស្គាល់ដែលហ្នឹង តែកុង ឡានគេមកដឹកយកទៅដាក់ ។

សុវណ្ណៈ ចឹងមិនមែនតាម៉ុក ទេ?

វ៉ន៖ មិនមានឃើញមេធំដូចជាតាម៉ុក អីទេ ឃើញតែឡានមកយក ។

សុវណ្ណៈ ឡាននិងឡានអីគេ?

វ៉ន៖ ឡានហ្នឹងសុទ្ធឡានខ្មែរក្រហមឡានអីម៉េច ។

សុវណ្ណៈ ឡានធំៗ?

វ៉ន៖ ឡានធំៗ ។

សុវណ្ណៈ ឡានទាហាន?

វ៉ន៖ ចាស!ឡានសេអ៊ីមសេ កង់១០គេហ្នឹង ។

សុវណ្ណៈ ចឹងឡានសេអ៊ីមសេ?

វ៉ន៖ ចាស!ឡានរបស់ចិនរបស់អាមេរិចនោះ ។

សុវណ្ណៈ ចឹងកាលហ្នឹងទៅគ្នាប៉ុន្មាននាក់ឬប៉ុន្មានឡានកាលហ្នឹងទៅភ្នំពេញ?

វ៉ន៖ មិនបានរាប់ផងមួយកងវរៈ ។

សុវណ្ណៈ មីងនៅទ័ពហ្នឹងខាងវរៈណាឬកងពលណាកាលហ្នឹង?

វ៉ន៖ កាលនៅតាកែវ គេរៀបកង៨៥អី គេមិនដាក់វរៈណាផង កាលហ្នឹងនៅទ័ពតំបន់ ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងនៅទ័ពតំបន់?

វ៉ន៖ ចាស!គេហៅទ័ពគេ ។

សុវណ្ណៈ ចឹងទ័ពតំបន់ណា?

វ៉ន៖ តំបន់១៣យើងហ្នឹង ។

សុវណ្ណៈ ចឹងកាលហ្នឹងពីណាគ្រប់គ្រងទ័ពតំបន់១៣?

វ៉ន៖ ខ្ញុំនឹកមិនឃើញទេ ចាំតែកងវរៈកងអីប្រធានកង ។

សុវណ្ណៈ ចឹងអ្នកគ្រប់គ្រងនៅទ័ពតំបន់១៣ហ្នឹង តាមុត?

វ៉ន៖ ចាស ។

សុវណ្ណៈ មិនមែនតាម៉ុកទេ?

វ៉ន៖ មានតាម៉ុក ណាឃើញតែតាមុតហ្នឹង ។

សុវណ្ណៈ ចុះតាសោម គាត់កាន់ខាងអីគេ?

វ៉នៈ ទេ មិនដឹងកាន់ខាងអី ខ្ញុំមិនសូវឃើញ ខ្ញុំឃើញតែតាមុតហ្នឹងតែម្ដង ។

សុវណ្ណៈ តាមុត ហ្នឹងក្មេងឬចាស់ កាលហ្នឹងអាយុប្រហែលជាប៉ុន្មាន?

វ៉នៈ មិនដឹងជាអាយុប៉ុន្មានទេ គាត់រៀងចំណាស់ដែរ ។

សុវណ្ណៈ ចឹងមីងនៅក្រោមការគ្រប់គ្រងរបស់តាមុតទៅ?

វ៉នៈ ចាស ។

សុវណ្ណៈ ចឹងមីងនៅវរៈណាកាលហ្នឹងទ័ពតំបន់ វរៈប៉ុន្មាន?

វ៉នៈ ដឹងវរៈណាបើខ្ញុំស្គាល់តែកងវរៈខ្ញុំហ្នឹង ។

សុវណ្ណៈ វរៈមីងកងវរៈស្អីគេ?

វ៉នៈ ប្រធានអង្គភាពហ្នឹងខ្ញុំអត់ដឹងថាណាទេ ខ្ញុំដឹងថាប្រធានស្រី ។

សុវណ្ណៈ ចឹងអ្នកគ្រប់គ្រងមីងផ្ទាល់ពីណាគេ?

វ៉នៈ ប្រធានកងធំយាយ សឿង ។

សុវណ្ណៈ ចឹងយាយសឿង ប្រធានកងធំ?

វ៉នៈ ចាស!ប្រធានកងធំ ប្រធានកងវរៈហ្នឹងបានយាយខាន ។

សុវណ្ណៈ ចឹងអត់មានឡើងទៅសមរភូមិណាឡើងទៅវាយនៅណាទេ?

វ៉នៈ ចាស ។

សុវណ្ណៈ នៅតែឈរជើងនៅខាងភ្នំដិនទៅ?

វ៉នៈ ចាស ។

សុវណ្ណៈ រហូតដល់ឆ្នាំ៧៥ បានគេដឹកទៅភ្នំពេញ?

វ៉នៈ ចាស ។

សុវណ្ណៈ គេដឹកទៅខាងណា ទៅភ្នំពេញហ្នឹង ទៅឈរជើងខាងណា?

វ៉នៈ នៅម្ដុំអន្លង់កាង៉ានអីហ្នឹង ។

សុវណ្ណៈ ចឹងទៅអន្លង់កាង៉ាន?

វ៉នៈ ចាស!ម្ដុំកប់ស្រូវអីហ្នឹង ។

សុវណ្ណៈ គេឲ្យទៅធ្វើអីគេនៅហ្នឹង?

វ៉នៈ គេឲ្យទៅលើកទំនប់ដីកប្រឡាយ ធ្វើស្រែអីហ្នឹង ។

សុវណ្ណៈ ចឹងនៅអន្លង់កាង៉ាននិងកប់ស្រូវ?

វ៉នៈ ចាស!នៅម្ដុំហ្នឹង គេហៅអីម្ដុំអន្លង់កាង៉ានម្ដុំខ្មញអីហ្នឹង ចឹងសំយាបអីហ្នឹង ។

សុវណ្ណៈ ចឹងនិយាយមីងសម្រាកអីហ្នឹងនៅម្តុំណា?

វ៉ន: ហ្នឹងនៅម្តុំហ្នឹងពេលមកភ្នំពេញ ចឹងទ័ពគេឲ្យមករៀនអីចឹង គេហៅយើងឲ្យទៅទទួលភ្ញៀវនៅភ្នំពេញហ្នឹងទៅ ។

សុវណ្ណៈ ចឹងមកភ្នំពេញ មកឈរជើងនៅម្តុំណា ដែលនៅជាប់ភ្នំពេញ?

វ៉ន: នៅម្តុំបុរីកីឡា ។

សុវណ្ណៈ ចឹងគេវាយបែកភ្លាមមីងមកភ្លាមតែម្តង?

វ៉ន: ចាស ។

សុវណ្ណៈ មកស្នាក់អាស្រ័យឈរជើងនៅម្តុំបុរីកីឡា?

វ៉ន: ចាស!តែបើស្នាក់នៅហ្នឹង នៅតែម្តុំអន្លង់កាង៉ាន ម្តុំខ្មួញ កប់ស្រូវម្តុំហ្នឹង តែដល់ពេលគេឲ្យមកទទួលភ្ញៀវចឹង មានមនុស្សច្រើនចឹងគេឲ្យយើងមកដាំបាយទទួលចឹងនៅម្តុំបុរីកីឡាស្តាតហ្នឹង ។

សុវណ្ណៈ ចឹងពេលមានពិធីមានភ្ញៀវយើងមកដាំបាយទទួលភ្ញៀវយើងមកស្នាក់នៅម្តុំបុរីកីឡា?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងកន្លែងដែលយើងឈរជើងជាប់មែនទែននៅម្តុំអន្លង់កាង៉ានទេ?

វ៉ន: ចាស!ម្តុំខ្មួញ ម្តុំអន្លង់កាង៉ានហ្នឹង ។

សុវណ្ណៈ នៅហ្នឹងនៅធ្វើអីគេ?

វ៉ន: នៅធ្វើស្រែ ។

សុវណ្ណៈ ចឹងក្រៅពីធ្វើស្រែមានធ្វើអីទៀត?

វ៉ន: អត់មានធ្វើអីទេ ពេលគេត្រូវការមកភ្នំពេញ មកទទួលភ្ញៀវ ទទួលហើយមកវិញមកធ្វើស្រែនៅហ្នឹង ។

សុវណ្ណៈ ចឹងយើងមានបោសសម្អាតប្រមែ៉ប្រមូលរបស់របរនៅក្នុងភ្នំពេញទេ ក្នុងទីក្រុងទេ?

វ៉ន: មានប្រមូលតើ គេឲ្យដឹកទឹកដោះគោ ដឹកទាំងពីទឹកអប់តាំងពី ។

សុវណ្ណៈ ដឹកយកមកតាមផ្ទះ?

វ៉ន: អត់ទេ ដឹកយកដាក់នៅម្តុំសាលាបាក់ទូក គេឲ្យដឹកឥវ៉ាន់យកមកដាក់ហ្នឹង ។

សុវណ្ណៈ មកដាក់ក្នុងឃ្លាំង?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងឃ្លាំងនៅម្តុំសាលាបាក់ទូកតែម្តុំផ្លូវដេហ្គោលឬយ៉ាងម៉េច មុនសាលាដែកមីង?

វ៉ន: ខ្ញុំជញ្ជូនជាមួយបង តែខ្ញុំទៅមែន តែខ្ញុំមិនសូវស្គាល់ក្រឡុកក្រលាគណា ។

សុវណ្ណៈ	ចឹងមុនគេនាំទៅភ្នំពេញហ្នឹង កាលពីមុនហ្នឹង មីងមានធ្លាប់មកភ្នំពេញទេ?

វ៉ន:	ពីមុនខ្ញុំមិនដែលទេ ។

សុវណ្ណៈ	មីងមិនដែលទៅភ្នំពេញទេ?

វ៉ន:	ចាស ។

សុវណ្ណៈ	មូលហេតុអីគេ?

វ៉ន:	មានមូលហេតុអីយើងក្រ យើងអត់ទៅយើងទៅណាបាន ។

សុវណ្ណៈ	មីងគិតថា ភ្នំពេញយ៉ាងម៉េច កាលមីងនៅក្មេងនោះ?

វ៉ន:	មានគិតថា ម៉េចពួកគេថាភ្នំពេញៗនោះ ពួកគេថាទៅសប្បាយចឹង ។

សុវណ្ណៈ	ចឹងដល់ពេលគេនាំមីងទៅភ្នំពេញហ្នឹង មីងមានអារម្មណ៍យ៉ាងម៉េចវិញកាលហ្នឹង យើងនៅក្មេងពួកគេទៅភ្នំពេញ កន្លែងសប្បាយកន្លែងល្អ?

វ៉ន:	ចាស ។

សុវណ្ណៈ	កាលមីងមិនទាន់បានទៅ?

វ៉ន:	ចាស ។

សុវណ្ណៈ	ចឹងដល់ពេលគេនាំទៅ មីងគិតថា ភ្នំពេញយ៉ាងម៉េចដែលពេលហ្នឹង?

វ៉ន:	ដឹងថា មិនសប្បាយបើប្រជាជនបាត់អស់រលីង ទីក្រុងគ្មានឃើញមានពីណា មានតែពួកយើងទ័ពនៅ ។

សុវណ្ណៈ	ចឹងស្ងាត់ជ្រាបភ្នំពេញ?

វ៉ន:	ចាស!មានតែកងទ័ពតាមកងពលហ្នឹង ។

សុវណ្ណៈ	ចឹងពេលឃើញភ្នំពេញស្ងាត់ចឹងមានអារម្មណ៍យ៉ាងម៉េចទៅវាខុសពីការគិតរបស់យើងពីមុនមកទេ?

វ៉ន:	ចាស ។

សុវណ្ណៈ	ខុសយ៉ាងម៉េចមីង?

វ៉ន:	ខុសអត់ឃើញសប្បាយអីគ្រន់ណា ។

សុវណ្ណៈ	ចឹងពេលហ្នឹងមីងគិតថា ភ្នំពេញយ៉ាងម៉េចដែរ?

វ៉ន:	មិនដឹងជាថាម៉េច អត់សប្បាយផង ។

សុវណ្ណៈ	ចឹងពេលយប់ឡើងទិដ្ឋភាពយ៉ាងម៉េចដែលនៅភ្នំពេញហ្នឹង?

វ៉ន:	យប់ឡើងមានស្អី ស្ងាត់ឈឹងហ្នឹង ។

សុវណ្ណៈ	ចុះភ្លើងអីមានបើកទេខ្លះទេ ភ្លើងពេលយប់ឡើងអី?

វ៉ន: ចាស! ភ្លើងមានដោយកន្លែង មានភ្លឺដូចយើងឥឡូវណា អត់មានទេ ។

សុវណ្ណៈ ចឹងយប់ឡើងមានពុស្គូវស្រមោលអីគេនៅភ្នំពេញ មានដែលពុស្រមោលអីជិះតាមថ្នល់ មានម៉ូតូឡានអីទេ មានច្រើនទេ?

វ៉ន: អត់ទេ ។

សុវណ្ណៈ ចឹងនិយាយទៅទិដ្ឋភាពដូចជាទីក្រុងខ្មោចដែរ?

វ៉ន: ចាស ។

សុវណ្ណៈ គ្មានកន្លែងសប្បាយអីទេ ចឹងមីងប៉ុន្មានខែប៉ុន្មានឆ្នាំគេឲ្យយើងទៅនៅខាងបុរីកីឡានោះគេច្រើនហើយយើងទៅនៅពេលណា?

វ៉ន: ទេ ហៅពេលណា ហៅពេលទទួលភ្ញៀវហ្នឹង ពេលត្រូវដាំបាយរៀនបន្តិចហ្នឹងមេៗគេមកពីខាងរតនគិរី មណ្ឌលគិរីចឹងទៅគេឲ្យយើងទៅដាំបាយទៅ តាប៉ុល ពត បង្រៀនចឹងយើងទៅណាស់ ។

សុវណ្ណៈ ចឹងមីងខាងចុងភៅទេ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងពេលទៅហ្នឹងរៀបចំខាងដាំបាយ រៀបចំខាងម្ហូបអាហារឲ្យគេ?

វ៉ន: ចាស! ពេលគេធ្វើឆ្អិនចឹងទៅ ចុងភៅធ្វើឆ្អិនយើងចាំទទួលទៅ ។

សុវណ្ណៈ ចឹងចាំលើកយកឲ្យគេ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងពេលគេមានវគ្គបំប៉នរៀននយោបាយឲ្យខាងទ័ព?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងមីងដាំបាយឲ្យទ័ពកាលហ្នឹង?

វ៉ន: ចាស! នៅខាងតំបន់ភូមិឃុំគេទៅរៀនចឹងទៅ គេជ្រើសរើសខាងប្រធានៗទៅរៀនយើងទៅៗទូទាំងប្រទេសចឹងទៅ ។

សុវណ្ណៈ គេខស្សាហ៍រៀនសូត្រវគ្គបំពាក់បំប៉ន់ទេ?

វ៉ន: ខស្សាហ៍រៀនដែលតើ ។

សុវណ្ណៈ ប៉ុន្មានខែរៀនម្តងឬប៉ុន្មានឆ្នាំរៀនម្តង?

វ៉ន: អត់ដល់ឆ្នាំទេ រៀនញឹក ក្រែងលោចេះខ្ញុំមិនបានដឹងមួយវគ្គចឹងទៅរើសខាងភូមិឃុំអីចឹងអ្នកដឹកនាំខាងកងទ័ពចឹង ខ្ញុំឃើញមកដេរុងចឹងឃើញគេរើសទ័ពមកបង្រៀនតាមកងពលអីចឹងទៅមក មានវគ្គគេរៀន ។

សុវណ្ណៈ	មីងមានដឹងថា ពីណាគេជាអ្នកបង្រៀនទេ?
វ៉នៈ	កាលហ្នឹងមានពីណាទេ មានតែតាប៉ុល ពត ។
សុវណ្ណៈ	ម៉េចមីងបានដឹងថា តាប៉ុល ពត កាលហ្នឹងមកបង្រៀន?
វ៉នៈ	មិនដឹងយ៉ាងម៉េចបើខ្ញុំបានឃើញគាត់ ។
សុវណ្ណៈ	ចឹងធ្លាប់ជួបដែរ?
វ៉នៈ	ចាស ។
សុវណ្ណៈ	គាត់មានភិនភាគយ៉ាងម៉េចដែលពេលហ្នឹង?
វ៉នៈ	កាលហ្នឹងគាត់ធាត់សាច់គាត់សស្អូសហ្នឹង ។
សុវណ្ណៈ	មីងគិតថា គាត់កាចទេ?
វ៉នៈ	ទេ ដូចជាមិនឃើញកាចអីផង មិនដែលឃើញគាត់ស្តីឲ្យពីណា គាត់ចេញមកឡានមកដល់ចឹង គាត់ចុះពីឡានមកទៅបង្រៀនទៅ បង្រៀនឯកសារអីហ្នឹង ខ្ញុំមិនសូវដឹងដែរ ខ្ញុំមិនថាកាចឬស្លូតអី ។
សុវណ្ណៈ	ចឹងមីងនៅភ្នំពេញដល់ឆ្នាំណាបានមកខាងរតនគិរីកាលហ្នឹង?
វ៉នៈ	យូរហើយដូចជាចង់ភ្លេចហើយ មើលទៅចុងឆ្នាំ៧៥ហ្នឹង ។
សុវណ្ណៈ	ចឹងឆ្នាំ៧៥?
វ៉នៈ	ចាស!កាលមួយយើងទទួលសម្តេចសីហនុ អាហ្នឹងឆ្នាំ៧៥ដែរ ។
សុវណ្ណៈ	ចឹងធ្លាប់បានទទួលសម្តេចសីហនុមកដែលកាលហ្នឹង?
វ៉នៈ	បានតើ ជាមួយបងអីហ្នឹង ។
សុវណ្ណៈ	ទៅទទួលនៅណា?
វ៉នៈ	នៅពោធិចិនតុង ។
សុវណ្ណៈ	មីងនៅក្នុងពោធិចិនតុងឬមីងនៅតាមផ្លូវទេ?
វ៉នៈ	ខ្ញុំនៅខាងសំយាបកន្លែងធ្វើស្រែហ្នឹង ដល់ពេលទទួលភ្ញៀវគេហៅយើងទៅ ។
សុវណ្ណៈ	ចឹងយើងស្លៀកពាក់យ៉ាងម៉េចទៅពេលហ្នឹង ពេលទៅទទួលសម្តេច គេឲ្យយើងស្លៀកពាក់ខ្មៅដដែលឬស្លៀកពាក់យ៉ាងម៉េច?
វ៉នៈ	ស្លៀកសំពត់ហូលអាវស ។
សុវណ្ណៈ	ចឹងអត់ឲ្យយើងស្លៀកខ្មៅទេ?
វ៉នៈ	ចាស ។
សុវណ្ណៈ	ចឹងឲ្យយើងស្លៀកសំពត់ហូលអាវសទៅ អាវបាក់ហ្នឹងមីង?

រ៉ន: អត់ទេ អាវសយើងធម្មតា ។

សុវណ្ណៈ អាវហ្នឹងយើងបានមកពីណា?

រ៉ន: មិនដឹងបានមកពីណាឃើញប្រកទាំងបេៗយកមកចែក ។

សុវណ្ណៈ ចឹងអាវហ្នឹងយើងទទួលហើយគេយកវិញឬយើងទុកខ្លួនយើង?

រ៉ន: គេយកទុកតាមកន្លែង ។

សុវណ្ណៈ ចឹងភាគច្រើនគេយកវិញទៅ មិនកាលហ្នឹងគេយកវិញទេ?

រ៉ន: ទេ ខ្ញុំកាលហ្នឹងដោះទុកនៅភ្នំពេញ កាលហ្នឹងខ្ញុំទទួលភ្ញៀវទៅយន្តហោះចុះមកខ្យល់ចាប់ខ្ញុំទៅដេកនៅពេទ្យភ្នំពេញទៅ ខ្ញុំដោះចោលនៅភ្នំពេញទៅ ។

សុវណ្ណៈ ចឹងកាលហ្នឹងយ៉ាងម៉េចបានខ្យល់មឹង មនុស្សច្រើនពេក?

រ៉ន: កាលហ្នឹងគេឲ្យនៅឈរជួរមុខគេទៀត គេថាប្រុងប្រៀបយន្តហោះជិតចុះហើយ ខ្ញុំគ្រាន់ឃើញយន្តហោះមកខ្ញុំដូចជាងងឹតឈ្ងប់ខ្យល់ចាប់ ។

សុវណ្ណៈ ចឹងមីងធ្លាប់ជួបសម្តេចពីមុនមកទេ?

រ៉ន: ពីមុនខ្ញុំមិនដែលបានជួបទេ ទើបជួបគាត់ម្តងនៅពោធិចិនតុង ។

សុវណ្ណៈ កាលហ្នឹងខែណា មានចាំទេ?

រ៉ន: អត់ចាំ បានត្រឹមទៅទទួលតែអត់បានចាំ ។

សុវណ្ណៈ ហើយធ្លាប់ទទួលពីណាទៀត ក្រៅពីសម្តេច?

រ៉ន: អត់ទេ បានទទួលភ្ញៀវតាមខេត្តតាមនេះ ។

សុវណ្ណៈ ចឹងទទួលភ្ញៀវធំៗចឹង ទទួលតាមព្រលានយន្តហោះ?

រ៉ន: មានពីណាចុះមានតែប្រពន្ធ សម្តេចសីហនុ អ្នកនាងម៉ូនីចនិងតាសីហនុ កូនចៅក្រុមគ្រួសារគាត់ ។

សុវណ្ណៈ ចឹងមីងទទួលបានតែម្តងហ្នឹងទេ?

រ៉ន: ទទួលបានពីរដង ។

សុវណ្ណៈ ចឹងពេលម្តងទៀតៗទៅទទួលខាងណា?

រ៉ន: គាត់ដែលហ្នឹង ។

សុវណ្ណៈ សម្តេចដែរ?

រ៉ន: ចាស!ម្តងបុពីរដងទេបង "អ្នកអគ្គុយជិតនិយាយថា ម្តងពោធិចិនតុងម្តងនៅស្អាត" ។

សុវណ្ណៈ ចឹងទៅស្អាតហ្នឹង យើងទៅទទួលកម្មវិធីអីគេ?

រ៉ន: ទេ គាត់មកហ្នឹង ។

សុវណ្ណៈ	បុណ្យបក្សប្តូក៏យ៉ាងម៉េច?

វ៉នៈ	ខ្ញុំមិនដឹងទេ ឃើញគាត់មក ចុះពីលើយន្តហោះមកយើងទៅទទួល ។

សុវណ្ណៈ	ខ្ញុំចង់និយាយថា ពេលនៅស្តាត?

វ៉នៈ	ស្តាតខួបទី១៧មេសា ។

សុវណ្ណៈ	កាលហ្នឹងស្តាតអូរឡាំពេជ្របុម្មួយស្តាតចាស់?

វ៉នៈ	ស្តាតចាស់ ។

សុវណ្ណៈ	ព្រោះស្តាតមានពីរ?

វ៉នៈ	ចាស ។

សុវណ្ណៈ	មានស្ពានជ្រោយចង្វាមួយស្តាតចាស់?

វ៉នៈ	ចាស ។

សុវណ្ណៈ	ហើយស្តាតជិតអូរឫស្សីគេហៅស្តាតអូរឡាំពេជ្រគេហៅស្តាតធំជាងគេបំផុតហើយ?

វ៉នៈ	មានម្តងទៀតនៅស្ទឹ កន្លែងបុរីកីឡានេះ ។

សុវណ្ណៈ	ហ្នឹងទទួលវគ្គដែលមករៀនទេ?

វ៉នៈ	ចាស!អាហ្នឹងទទួលខាងអី គណៈឃុំ គណៈស្រុក គណៈខេត្តគេនោះ មកពីមណ្ឌលគិរីរតនគិរី អីហ្នឹង សុទ្ធមានចោះត្រចៀក ។

សុវណ្ណៈ	ចឹងខាងជនជាតិ?

វ៉នៈ	ចាស!ឃើញមករៀនហ្នឹង ។

សុវណ្ណៈ	ជនជាតិអីគេ?

វ៉នៈ	ពួកភ្នង ។

សុវណ្ណៈ	មានភ្នងមានអីគេទៀត?

វ៉នៈ	ទៅពីមណ្ឌលគិរី រតនគិរីតែមិនដឹងជាជនជាតិអី ឃើញគាត់ចោះត្រចៀកពាក់ ។

សុវណ្ណៈ	បាទ!មានភ្នង មានទំពួនអី មានចារាយ ចឹងមីងចុងឆ្នាំ៧៥មីងទៅណា?

វ៉នៈ	មាននៅណានៅរតនគិរីហ្នឹង ។

សុវណ្ណៈ	ទៅរតនគិរី?

វ៉នៈ	ចាស ។

សុវណ្ណៈ	ទៅជាមួយខាងកងពលណា?

វ៉នៈ	កងពល៨០១ហ្នឹង ។

សុវណ្ណៈ	មីងទៅជាមួយពូដែរ?

វ៉ន៖ ហ្នឹងហើយទៅទាំងអស់គ្នាហ្នឹង ។

សុវណ្ណៈ ចឹងនៅជាមួយគ្នា?

វ៉ន៖ ចាស ។

សុវណ្ណៈ កងពល៨០១ទៅឈរជើងខាងណាមីង?

វ៉ន៖ នៅខាងបានលុងវឺនសៃនោះ ។

សុវណ្ណៈ តែមីងទៅឈរជើងខាងណាដំបូង?

វ៉ន៖ ទៅដល់ដំបូងនៅហ្នឹង នៅបានលុង ។

សុវណ្ណៈ ចឹងបន្ទាប់មកទៅខាងណាទៀត ពេលទៅបានលុងហើយ?

វ៉ន៖ អត់ទេ ហើយវត់ចេញពីហ្នឹងបែកខ្ញែកគ្នាមក ។

សុវណ្ណៈ ចឹងដល់៧៩បាត់ហើយ?

វ៉ន៖ យួនវាវាយមក ។

សុវណ្ណៈ ចឹងបានបានលុងរហូតដល់វត់តែម្តង?

វ៉ន៖ ចាស ។

សុវណ្ណៈ ចឹងកាលនៅបានលុងនៅហ្នឹងធ្វើអីគេ?

វ៉ន៖ មានធ្វើអីធ្វើស្រែចម្ការ ។

សុវណ្ណៈ តែមីងនៅទ័ពដដែលទេ?

វ៉ន៖ ចាស!នៅដដែល ។

សុវណ្ណៈ មីងកាលហ្នឹងនៅខាងកងពល៨០១?

វ៉ន៖ ចាស ។

សុវណ្ណៈ តែមីងនៅខាងទ័ពនារីទេ?

វ៉ន៖ ចាស ។

សុវណ្ណៈ តែនៅក្នុងកងពល៨០១?

វ៉ន៖ ចាស!ហ្នឹងហើយក្តោបក្តាប់នៅក្នុងកងពល៨០១ ។

សុវណ្ណៈ វរសេនាធំលេខប៉ុន្មាន?

វ៉ន៖ កងពលតែម្តង៨០១ហ្នឹង ។

សុវណ្ណៈ តែនៅក្នុងវរសេនាធំលេខប៉ុន្មាន អត់អីទេ មីងតាមពិតនៅក្នុងកងពល៨០១?

វ៉ន៖ ចាស ។

សុវណ្ណៈ តែនៅក្នុងកងពលធំគេចែកចេញជាកងវរៈរបស់គេ?

វ៉ន: ចាស! វាមានវរសេនាធំ ។

សុវណ្ណ: មានវរសេនាធំប៉ុន្មាន?

វ៉ន: អត់ទេ ខ្ញុំនៅក្នុងមន្ទីរកងពលហ្នឹងតែម្តង ។

សុវណ្ណ: ចឹងនៅក្នុងមន្ទីរកងពល?

វ៉ន: ចាស ។

សុវណ្ណ: ហើយកិច្ចការធ្វើអីគេ?

វ៉ន: សេដ្ឋកិច្ច ។

សុវណ្ណ: ខាងសេដ្ឋកិច្ចចឹង ខាងបង្កបង្កើនផល?

វ៉ន: ខ្ញុំនៅជាមួយយាយសឿង នៅកងមន្ទីរវរៈទាំងអស់ ដូចថាកងពលនៅត្រង់ហ្នឹងចឹងពួកខ្ញុំនៅចឹងនេះនៅក្បែរគ្នា ។

សុវណ្ណ: ចឹងមីងនៅខាងសេដ្ឋកិច្ចខាងបង្កបង្កើនផល?

វ៉ន: ចាស! នៅទាំងអស់គ្នាតែម្តងនារីនៅកន្លែងហ្នឹង ។

សុវណ្ណ: មួយកងនារីរបស់មីងមានគ្នាប៉ុន្មាននាក់ ក្នុងកងពល៨០១ហ្នឹង កងនារីមានប៉ុន្មាននាក់ទៅវរសេនាតូចមានប៉ុន្មាននាក់?

វ៉ន: មិនដឹងជាប៉ុន្មានរយនាក់តែមានបីកងធំ ។

សុវណ្ណ: មានបីកងធំ?

វ៉ន: ចាស! ប្រហែលជា៣០០នាក់ ។

សុវណ្ណ: ចឹងប្រហែលជា៣០០នាក់?

វ៉ន: ចាស ។

សុវណ្ណ: ចឹងភាគច្រើនមកពីខាងណា?

វ៉ន: មកពីតាកែវ ។

សុវណ្ណ: ភាគច្រើនមួយកងហ្នឹងទាំងអស់តែម្តង?

វ៉ន: ទេ តាកែវ បងច្រើនពីតាកែវមកយើង ហើយមានខាងកណ្តាលស៊ីង គេបញ្ចូលខ្លះទៀតមានគ្រប់ភូមិស្រុកហ្នឹងឯង ចូលភ្នំពេញហើយ ។

សុវណ្ណ: ចឹងកាលហ្នឹងមីងផ្លាស់មកខាងរតនគិរី?

វ៉ន: ទេ កាលហ្នឹងគេហៅមកតែម្តង ។

សុវណ្ណ: ម៉េចបានគេផ្លាស់មក មានហេតុអី?

វ៉ន: អត់មានដឹងគេហៅមកតែម្តង មកទាំងកងតែម្តង ។

សុវណ្ណៈ ចឹងមកនៅហ្នឹងការងារប្រចាំថ្ងៃយើងធ្វើអីគេនៅបានលុងហ្នឹង?

វ៉ន: ធ្វើស្រែចម្ការហ្នឹង ដល់ឲ្យកងទ័ពដែលហ្នឹង ។

សុវណ្ណៈ ចឹងការហូបចុក កាលហ្នឹងមានខ្វះខាតឬមួយមិនខ្វះខាតទេពេលហ្នឹង?

វ៉ន: ថា ខ្វះវាមិនខ្វះដែរ ថាសម្បូរគ្មានអីគួរសម្បូរដែរ ក្នុងនាមសន្សំសំចៃ ។

សុវណ្ណៈ ចឹងមីងយើងធ្វើបង្កបង្កើនផលបានយើងយកទៅខាងណាវិញ?

វ៉ន: ឲ្យទ័ព ។

សុវណ្ណៈ ឲ្យទ័ពខាងណាវិញ?

វ៉ន: ឲ្យទ័ពសមរភូមិខាង៨០១ហ្នឹងតែម្តង ។

សុវណ្ណៈ ទ័ពខាងជួរមុខ?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងមានបានឡើងទៅវាយជួរមុខខ្លះទេ?

វ៉ន: អត់ទេ អត់មានទេ ស្រីៗទៅដល់ហ្នឹងគេឲ្យទៅខាងបង្កបង្កើនផលជួយឧបត្ថម្ភកងទ័ព ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងចេញពីផ្ទះនៅឆ្ងាយពីបងប្អូននៅឆ្ងាយពីឪពុកម្តាយចឹង យើងមាននឹករលឹកដល់គ្រួសារអីខ្លះទេមីង?

វ៉ន: នឹកហួសពីនឹកហើយតែមិនដឹងជាធ្វើយ៉ាងម៉េច ដែលគេឲ្យយើងមកសម័យនោះ ហ៊ានមកគ្មានច្បាប់ដឹងថាបាត់ខ្លួន ។

សុវណ្ណៈ ចឹងយើងទាក់ទងគ្រួសារយ៉ាងម៉េចទៅ?

វ៉ន: អត់ទេ អត់មានបានទាក់ទង ។

សុវណ្ណៈ ចឹងមានលួចទាក់ទងសរសេរសំបុត្រតាមគេអីមានទេ?

វ៉ន: អត់មានទេ ។

សុវណ្ណៈ ចឹងបានន័យថា ដាច់ទំនាក់ទំនងតាំងពីឆ្នាំ៧០មកហូតមក?

វ៉ន: ចាស ។

សុវណ្ណៈ ចឹងកាលហ្នឹងមីងមានដែលសុំគេទៅលេងផ្ទះទៅលេងបងប្អូនអីទេ?

វ៉ន: សុំតើ គេមិនឲ្យទៅ ។

សុវណ្ណៈ គេថាយ៉ាងម៉េច?

វ៉ន: គេមិនឲ្យទៅ ។

សុវណ្ណៈ ចឹងយើងសុំគេថាយ៉ាងម៉េច?

វ៉ន: សុំគេថាទៅលេងផ្ទះតែគេថាមិនឲ្យទៅ កាលបែកភ្នំពេញខ្ញុំសុំដែរ ។

សុវណ្ណៈ គេមានប្រាប់មូលហេតុយើងទេ អត់ឲ្យយើងទៅចឹង?

រ៉នៈ គេប្រាប់ថា មិនឲ្យទៅតែម្តង គេថាអត់ទាន់មានច្បាប់ឲ្យទៅដើរលេងទេ ។

សុវណ្ណៈ ចឹងមីងគិតថា របបហ្នឹងពេលហ្នឹងយ៉ាងម៉េចទៅ?

រ៉នៈ របបហ្នឹងមានម៉េច មានតែផ្តាច់ការតែម្តង យើងនឹកក្នុងចិត្តយើងតែយើងមិនហ៊ាននិយាយ យើងគ្រាន់ថា ចិត្តអាក្រក់ពេកហើយ អត់ឲ្យទៅលេងក្រុមគ្រួសារនឹកតែក្នុងចិត្តយើង ។

សុវណ្ណៈ តែយើងមិនហ៊ាននិយាយទេ?

រ៉នៈ អត់ ។

សុវណ្ណៈ ចឹងពេលហ្នឹង យើងមានលំបាកចិត្តម្តង មានអ្នកពិភាក្សាជាមួយយើងខ្លះទេមីង?

រ៉នៈ អត់ទេ គេមានពិភាក្សាអីសួរ ថាយើងពិបាកចិត្តអីចេះចុះអត់ទេ ។

សុវណ្ណៈ ឧបមាថា ឥឡូវយើងជួបពិបាកចិត្តអី យើងមានអ្នកជិតខាងយើងនិយាយគ្នាលេងសើចអីខ្លះបានទេ ចឹងពេលសម័យហ្នឹង យើងពិបាកចិត្តយើងរកពីណានិយាយគ្នាលេងបាន?

រ៉នៈ មានមិត្តភក្តិយើងដែលជិតស្និតចេះតែនិយាយគ្នាទៅណាស់ យើងចេះតែនិយាយរឿងនឹកផ្ទះអី តែយើងគ្មានសង្ឃឹមបានទៅ ។

សុវណ្ណៈ ចឹងយើងនិយាយជាចំហឬមួយនិយាយលួចលាក់ដែរ?

រ៉នៈ និយាយលួចលាក់ ។

សុវណ្ណៈ ចឹងអត់លួចហ៊ាននិយាយជាចំហទេ?

រ៉នៈ អត់ទេ យើងខ្លាចគេ ព្រោះគេដឹកនាំយើង ។

សុវណ្ណៈ ខ្លាចអីគេ?

រ៉នៈ ខ្លាចគេសម្លាប់ចោល ។

សុវណ្ណៈ ខ្លាចគេយកទៅណាបើគេដឹង?

រ៉នៈ គេដឹងគេយកទៅណាគេអប់រំ កសាងយើងគេដាក់ពិន័យតឹងរឹងទៅ ។

សុវណ្ណៈ មីងមានគេហៅទៅអប់រំហៅទៅកសាងមានដែលបានត្រឡប់មកវិញខ្លះទេ?

រ៉នៈ អត់ទេ ពួកខ្ញុំមិនដែលហ៊ាននិយាយអីទេ តែមានដូចគេហៅថាម៉េច អ្នកមានរយៈអ្នកមានបងប្អូនដូចថាខ្សែខាងនេះខាងនោះចឹង គេយកទៅរៀន ទៅដាក់កន្លែងផ្សេងចឹង ។

សុវណ្ណៈ ចឹងអ្នកដែលគេហៅទៅរៀនសូត្រហ្នឹងភាគច្រើនគេឲ្យមកវិញខ្លះទេឬគេយកទៅរៀនសូត្រនៅខាងណាខាងណើអីមានដឹងទេ?

រ៉នៈ មានស្អីពួកខ្ញុំគេមិនដែលយកទៅណាផង គ្រាន់គេយកទៅណែនាំកន្លែងគេអប់រំ ។

សុវណ្ណៈ ចឹងនៅក្នុងក្រុមរបស់មីងមានដែលមានអ្នកបាត់ខ្លួនទេ?

រ៉ន:	អត់ទេ អត់មានបាត់ទេ ។

សុវណ្ណៈ	ចឹងកាលហ្នឹងយើងរត់នៅឆ្នាំណា ពេលរត់នៅរតនគិរីហ្នឹង ពេលវៀតណាមវាយចូលមកអីហ្នឹង?

រ៉ន:	អាហ្នឹង៧៩ យើងរត់បែកខ្ញែកគ្នាមកនេះឆ្នាំ៧៩ ។

សុវណ្ណៈ	មានចាំថាខែណា?

រ៉ន:	អត់មានចាំទេ ចុះនៅតាមព្រៃចេះមានដឹងអី យើងមានស្អីស្គាល់យើងមានដឹងអី នៅតែក្នុងព្រៃគ្មានខែថ្ងៃអីទេ ។

សុវណ្ណៈ	ចឹងយើងមានដឹងសភាពការណ៍មុនទេ មុននិងយើងរត់បែកផ្លូវគ្នាហ្នឹង យើងមានដឹងមុនខ្លះៗហើយនៅថា ទ័ពវៀតណាមគេវាយចូលមក មានដឹងខ្លះនៅមិន?

រ៉ន:	កាលរត់ទាំងកងមកហ្នឹងដឹង ដល់ពេលមកនៅក្នុងព្រៃបែកគ្នាមកតាមក្រុមតាមអីហ្នឹងក្នុងព្រៃហ្នឹងអត់មានដឹងទេ ។

សុវណ្ណៈ	ចឹងពេលវៀតណាមវាយចូលមកយើងរត់ចូលព្រៃ?

រ៉ន:	ចាស ។

សុវណ្ណៈ	ចឹងពេលរត់ចូលព្រៃយើងរត់មកខាងណាទៀត?

រ៉ន:	មានរត់ទៅណារត់ឡើងមកលើភ្នំហ្នឹង ។

សុវណ្ណៈ	ភ្នំណាកាលហ្នឹង?

រ៉ន:	យើងរត់មករកភ្នំដងរែកហ្នឹង ។

សុវណ្ណៈ	ភ្នំដងរែកតែយើងទៅតំបន់ណា?

រ៉ន:	មិនដឹងជាតំបន់ប៉ុន្មានទេ ពេញវាលពេញទឹកពេញដី ។

សុវណ្ណៈ	ដឹងថា នៅ១០០១-១០០២-១០០៣?

រ៉ន:	ចាស!រត់ទៅខាង១០០១ ។

សុវណ្ណៈ	ចឹងទៅដល់១០០១ហ្នឹងយើងធ្វើដំណើររយៈពេលប៉ុន្មានបានយើងទៅដល់?

រ៉ន:	កាលហ្នឹងឡានដឹកកាត់ប្រទេសថៃហើយ ឆ្លងថៃហើយបានមកនៅ១០០១ហ្នឹង ។

សុវណ្ណៈ	ចឹងកាលធ្វើដំណើរមក១០០១ កាលហ្នឹងយ៉ាងម៉េចដែលលំបាកទេ?

រ៉ន:	ជិះឡានគេមានឲ្យយើងឈប់ ។

សុវណ្ណៈ	ចឹងមិនមែនដើរទេជិះឡាន?

រ៉ន:	ចាស ។

សុវណ្ណៈ	ពីណាគេទៅយកពេលហ្នឹង?

វ៉ន: មិនដឹងជាខាងណាទេ ឡូទៅយក ។

សុវណ្ណៈ តែយើងរត់ចូលព្រៃនៅខាងណាបានគេទៅយកយើង ជិះតាមថៃមកវិញបាន?

វ៉ន: យើងរត់មកនៅថៃ ដល់ចឹងគេដឹកឆ្លងមកដល់ព្រំដែនទន្លេល្អៅហ្នឹងបានគេកាត់ទៅថៃ ។

សុវណ្ណៈ ចឹងនៅ១០០១មានគេហៅឈ្មោះអីផ្សេងទៀតទេ មានហៅតំបន់អីមួយទៀតទេ?

វ៉ន: ខ្ញុំអត់នេះទេ ខ្ញុំរត់មកបន្តិចចឹងយើងមកនៅនេះទៀតមក ។

សុវណ្ណៈ ចឹងមីងនៅ១០០១បានប្រហែលជាប៉ុន្មានឆ្នាំ?

វ៉ន: អត់ទេ នៅបានប្រហែលជាប៉ុន្មានខែ គេដឹកមកវិញទៀត ។

សុវណ្ណៈ បានប៉ុន្មានខែមីង?

វ៉ន: បានប៉ុន្មានខែទេ មិនបានមួយខែផង ។

សុវណ្ណៈ ចឹងក្រោយមកយើងរត់ទៅណាទៀត?

វ៉ន: ក្រោយមករត់មកនៅហ្នឹងតែម្តង ។

សុវណ្ណៈ មកខាងណាមុនមីង?

វ៉ន: មកនៅកន្លែងអូរស្មាច់ ហើយបានមកនៅហ្នឹងទៀត ។

សុវណ្ណៈ ចឹងយើងអត់មានរត់ទៅខាង១០០២-១០០៣សិនទេ?

វ៉ន: អត់ទេ ។

សុវណ្ណៈ ក្រោយមកយើងទៅ១០០៣ ក្រោយមកយើងចុះមកក្រោមយើងចុះមកឆ្នាំណា?

វ៉ន: ឆ្នាំណាទេ ខ្ញុំមិនសូវចាំ ។

សុវណ្ណៈ យើងចុះមកក្រោម ចឹងបានន័យថា យើងនៅ១០០១រហូតដល់យើងចុះភ្នំឬយើងរត់ពី ១០០១ទៅ១០០២ឬទៅ១០០៣ទៀតទេ មានរត់ទៅកន្លែងផ្សេងទៀតទេ?

វ៉ន: អត់ទេ ។

សុវណ្ណៈ ចឹងនៅ១០០២ពេលគេវាយ១០០១បានយើងចុះមកក្រោមមក?

វ៉ន: ចាស ។

សុវណ្ណៈ ចុះមកក្រោមចុះមកឆ្នាំណា ឆ្នាំ៩០ឬក៏ខ្ទង់៩០ប៉ុន្មាន?

វ៉ន: ខ្ញុំគ្មានចាំទេ ។

សុវណ្ណៈ ចឹងចុះមកដល់ដំបូងយើងមកនៅកន្លែងណា?

វ៉ន: មកដំបូងមកនៅខាងអូរស្មាច់ អូរស្មាច់ហើយមកហ្នឹងមក ។

សុវណ្ណៈ ចឹងនៅអូរស្មាច់ហើយឆ្នាំណាបានមកនៅខាងនេះ សមាហរណ៍កម្មហើយ?

វ៉ន: សមាហរណ៍កម្មនៅនេះ ។

សុវណ្ណៈ យើងមកផ្តាច់ខ្លួនមុន?

វ៉ន: មកមុនផ្តាច់ខ្លួន បានប្រហែលជាមួយឆ្នាំបានគេធ្វើសមាហរណ៍កម្ម កាលអ៊ុនតាក់ឆ្នាំ៩៣ ។

សុវណ្ណៈ ចឹងមកពេលអ៊ុនតាក់?

វ៉ន: អ៊ុនតាក់ហើយបានមកនេះ ។

សុវណ្ណៈ ចេញពីអូរស្វាយមកនេះតែម្តង?

វ៉ន: ចាស ។

សុវណ្ណៈ ម៉េចបានជាយើងមកខាងនេះមីង មានអ្នកនាំយើងមកឬក៏យ៉ាងម៉េចយើងមកខ្លួនឯង?

វ៉ន: មកតាមអង្គភាព ដូចថាមេៗគេឲ្យមកនៅហ្នឹង យើងមកនៅមក ។

សុវណ្ណៈ ពេលមកនៅដំបូងនៅនេះយ៉ាងម៉េចដែលមីង ជាតំបន់យ៉ាងម៉េច តំបន់ព្រៃ?

វ៉ន: ព្រៃតាមហ្នឹង មកដល់ដំបូងព្រៃ ។

សុវណ្ណៈ មីនសម្បូរទេ?

វ៉ន: សម្បូរដែរ ខាងស៊ីម៉ាក ខាងឡូ គេមកវាវដែរ ។

សុវណ្ណៈ មីនកាលហ្នឹងខាងណាអ្នកដាក់ខ្លះមីង មានដឹងទេ?

វ៉ន: ខ្មែរក្រហមហ្នឹង ។

សុវណ្ណៈ យើងហ៊ានដើរទៅណាទៅណីផ្តេះផ្តាស់បានទេ?

វ៉ន: ដើរ ខ្លះគេធ្លាប់ស្គាល់អីចឹង ដល់នេះខាងស៊ីម៉ាក ខាងឡូគេមកវាវចឹងទៅ ។

សុវណ្ណៈ ចឹងពេលបច្ចុប្បន្ននេះ មីងយល់ឃើញយ៉ាងម៉េចដែលជីវិតរស់នៅពេលនេះ?

វ៉ន: ឥឡូវមានស្អីផង ។

សុវណ្ណៈ ចង់និយាយថា ជីវិតយើងគ្រាន់បើជាងពីមុនឬយើងនៅពិបាកដូចមុន?

វ៉ន: ឥឡូវម៉េចពិបាកដូចមុន ពីមុននៅតាមព្រៃតាមផ្សៃពិបាក ឥឡូវបានមកនៅភូមិអី ។

សុវណ្ណៈ ចឹងមីងពេញចិត្តជីវិតរស់នៅក្នុងពេលនេះទេ?

វ៉ន: ពេញ ។

សុវណ្ណៈ ព្រោះថាពីមុនធ្លាប់រត់កាត់គ្រាប់?

វ៉ន: ចាស ។

សុវណ្ណៈ រឹតត្បិតមិនឲ្យជួបបងប្អូន រត់ទៅនេះបន្តិចទៅនោះបន្តិច ដល់ពេលឥឡូវយើងនៅតែមួយកន្លែង យើងមានសេរីភាពចង់លទៅណាក៏បាន អត់មានពីណាហាមឃាត់?

វ៉ន: ចាស ។

សុវណ្ណៈ មុនទៅណាទាល់តែសុំគេអី?

វ៉ន៖ ចាស ។

សុវណ្ណ៖ ចឹងមីងពេញចិត្តរស់នៅពេលនេះទេ?

វ៉ន៖ ចាស ។

សុវណ្ណ៖ ឬមួយមិនពេញចិត្តទេ?

វ៉ន៖ ពេញចិត្ត ។

សុវណ្ណ៖ មូលហេតុអីបានជាមីងពេញចិត្ត?

វ៉ន៖ ពេញចិត្តយើងរស់នៅស្រួល កូនយើងបាននៅស្រួលយើងមិនរត់លូនដូចមុន ខ្ញុំស្តាយតែកូននៅស្ទាវរត់ចុះឡើងចង់ងាប់ហើយ ។

សុវណ្ណ៖ ចឹងមីងយល់ឃើញយ៉ាងម៉េចដែលសព្វថ្ងៃនេះគេមានដាក់បង្រៀនរឿងរបបខ្មែរក្រហមនៅក្នុងសាលារៀនមីង?

វ៉ន៖ ចាស ។

សុវណ្ណ៖ យើងមីងគិតថា ក្មេងទាំងអស់ហ្នឹងគួរតែរៀនរឿងរ៉ាវទាំងអស់ដើម្បីឲ្យបានដឹងឮឬមួយមិនគួរបង្រៀនទេមីង?

វ៉ន៖ រឿងហ្នឹងខ្ញុំមិនដឹងដែរ ។

សុវណ្ណ៖ តែសម្រាប់មីង មីងគិតថារឿងទាំងអស់ហ្នឹងគួរឲ្យក្មេងរៀនឬមិនគួរឲ្យក្មេងរៀន ព្រោះថាក្មេងៗឥឡូវគេមានរៀនរឿងរ៉ាវរបបបីឆ្នាំនៅតាមសាលារៀន មីងគិតថាវាសំខាន់ដែលអត់ គិតថារៀនដឹងឮរឿងរ៉ាវរបបហ្នឹងសំខាន់ឬមិនសំខាន់ទេ?

វ៉ន៖ មិនដឹងជាយ៉ាងម៉េចខ្ញុំមិនចេះថាដែរ ថាទៅក្រែងលោខុស ។

សុវណ្ណ៖ ថាទៅមីងមិនអីទេ គិតថាវាសំខាន់គួររៀនឬមិនគួររៀន?

វ៉ន៖ ចឹងបើយើងបង្កើតថ្មីទៀតហើយ យើងមិនគួររៀនទេដឹង ។

សុវណ្ណ៖ រៀនឬមិនគួររៀនមីង បើយើងរៀនទៅឲ្យក្មេងៗបានដឹងឮរបបពីមុនកុំឲ្យវាត្រឡប់មកវិញ ចឹងមីងគិតថារៀនឬមិនគួររៀនមីង?

វ៉ន៖ គួរតែរៀនទៅ ឲ្យក្មេងៗវាដឹងអស់ទៅ ។

សុវណ្ណ៖ ចឹងម៉េចមីងថាគួរតែរៀនចឹង?

វ៉ន៖ ចុះឥឡូវក្មួយថា គេបង្កើតតាមសាលាហើយ គេចង់ឲ្យក្មេងៗដឹងថារបបហ្នឹងវាយ៉ាងម៉េច ។

សុវណ្ណ៖ ចឹងមីងមានអីចង់សួរនាំខ្លះទេ ខ្ញុំបានសួរមីងច្រើនហើយ?

វ៉ន៖ អត់ទេ ខ្ញុំអត់មានអីត្រូវសួរផង ។

សុវណ្ណ៖ មីងមានអីចេញជាយោបល់ខ្លះទេ?

រ៉ន:	អត់ទេ ។

សុវណ្ណ:	ចឹងសម្រាប់ខ្លួនផ្ទាល់របស់មីងវិញ មីងយល់ថា ការរៀនសូត្រហ្នឹងវាសំខាន់ទេឬក៏មិនសំខាន់ទេ មីង?

រ៉ន:	ឥឡូវខ្ញុំមាននិយាយអីច្រើន ខ្ញុំគ្រាន់និយាយថា បើសិនជាប្រទេសជាតិយើងថ្ងៃមុខក្លាយៗរៀបរយបានស្រួលនិងខ្ញុំអរកុំឲ្យមានកើតសង្គ្រាមដូចជំនាន់ខ្ញុំទៀត ជំនាន់ខ្ញុំឆ្អែតអស់ហើយ ពិបាកមាំណាស់ ។

សុវណ្ណ:	ចឹងនៅពេលនេះមីងមានអីកន្លែងណាដែលមីងមិនពេញចិត្តខ្លះទេមីង ចំណុចដែលមិនពេញចិត្តចំពោះការដឹកនាំក្នុងពេលនេះ មីងមានទេ?

រ៉ន:	ឥឡូវមានអី ធ្វើម៉េចឲ្យតែប្រជាជនរស់បានស្រួលទៅ មានទឹកមានដីកូនចៅយើងទៅមុខស្រួលកុំឲ្យមានជំពាក់អីទៀត កុំឲ្យមានគេឯងមកជ្រែតជ្រែកនៅក្នុងទឹកដីយើងតែប៉ុណ្ណឹងទេខ្ញុំគិតចឹង ។

សុវណ្ណ:	ចឹងសម្រាប់មីងផ្ទាល់នៅក្នុងរបបបីឆ្នាំមកហើយចឹង និងរស់នៅពេលនេះនិងមើលត្រឡប់ទៅខាងក្រោយវិញ គិតថារបបបីឆ្នាំយ៉ាងម៉េចដែរ ជារបបយ៉ាងម៉េចដែរ?

រ៉ន:	របបហ្នឹងខ្ញុំមិនចង់ ។

សុវណ្ណ:	របបហ្នឹងយើងទៅណាមិនបាន?

រ៉ន:	ចាស ។

សុវណ្ណ:	គ្មានសិទ្ធសេរីភាពចឹង?

រ៉ន:	ចាស ។

សុវណ្ណ:	ចឹងមីងគិតថារបបហ្នឹងជារបបយ៉ាងម៉េច រស់នៅក្រោមការគៀបសង្កត់របស់គេ មានការភ័យខ្លាច គិតថារបបខ្មែរក្រហមជារបបយ៉ាងម៉េច?

រ៉ន:	របបខ្មែរក្រហមកាលនោះជារបបផ្ដាច់ការ ឃាត់ឃាំងយើងមិនឲ្យទៅណាតាមចិត្ត ។

សុវណ្ណ:	ចឹងខ្ញុំដូចជាអស់ហើយមីង ។

រ៉ន:	ចាស ។

សុវណ្ណ:	ខ្ញុំរំខានមីងច្រើនមកហើយ ចឹងខ្ញុំអរគុណមីងច្រើន ។

រ៉ន:	ចាស! អរគុណ ។

**ចប់**